ក

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

៣១-៨-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៨០៧/៣៩៧ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ដូរូស៊ីនកូ អូស្តាប់** (DOROSHENKO OSTAP) ជនជាតិរុស្ស៊ី សញ្ជាតិរុស្ស៊ី កើតនៅ តំបន់អាល់ម៉ាលីក ក្រុងតាស្កែន ប្រទេសអ៊ូបេគីស្ថាន ៧៣១១

៣១-៨-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៨០៧/៣៩៨ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់ :

-កុមារី **អេយ៉ី យៀនចាន់អោងអែត សឺរីន ស្វង** (AYE NYEIN CHAN AUNG @ SERENE ZHUANG) ជនជាតិភូមា សញ្ជាតិភូមា កើតនៅក្រុងយ៉ាងហ្គូន ប្រទេសភូមា

-កុមារា **សេយ៉ា អោងអែត វីនសុន ស្វង** (ZE YA AUNG @ VIN SON ZHUANG) ជនជាតិភូមា សញ្ជាតិភូមា កើតនៅក្រុងយ៉ាងហ្គូន ប្រទេសភូមា ៧៣១២

៣១-៨-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៨០៧/៣៩៩ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់កញ្ញា **អេយ៉ី ធីដាអោងអែត វិចតូរីយ៉ា ស្វង**(AYE THIDAR AUNG @ VICTORIA ZHUANG) ជនជាតិភូមា សញ្ជាតិភូមា កើតនៅក្រុងយ៉ាងហ្គូន ប្រទេសភូមា ៧៣១៣

៣១-៨-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៨០៧/៤០០ ស្តីពីការកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ,ក្របខ័ណ្ឌគ្រូបង្រៀនកំរិតឧត្តម និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី, គ្រូបង្រៀនកំរិតឧត្តម តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងធម្មការ និងសាសនា ៧៣១៤

01-9-2007 -KRET NS/KRT/0907/401 ÉLEVONS Son Excellence Monsieur Sar Chanrithy au rang de Directeur Général. ៧៣១៧

០៤-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤០២ ស្តីពីការតែងតាំងលោក **គីម ខួន** ជាឧកញ៉ា ៧៣១៨

០៤-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤០៣ ស្តីពីការតែងតាំងឯកឧត្តម **សាមួន ជន** ជាទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ រដ្ឋលេខាធិការ ៧៣១៩

០៤-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤០៤ ស្តីពីការតែងតាំងឯកឧត្តមចំនួន ០២ រូប ជាទីប្រឹក្សាឯកឧត្តម **ខួន ញឹម** អនុប្រធាន ទី ១ នៃរដ្ឋសភា នីតិកាលទី ៣ ៧៣២០

០៦-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤០៥ ស្តីពីការតម្លើងថ្នាក់ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ជូនឯកឧត្តម **ម៉ៅ តិរុណ** ពីឧត្តមមន្ត្រីថ្នាក់លេខ ៣ ទៅឧត្តមមន្ត្រីថ្នាក់លេខ ២ ៧៣២១

០៦-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤០៦ ស្តីពីការតែងតាំងឯកឧត្តម,លោកជំទាវ, ព្រះអង្គម្ចាស់ ចំនួន ០៤ រូប ជាឧបនាយករដ្ឋមន្ត្រី,ជាទេសរដ្ឋមន្ត្រី និងជារដ្ឋលេខាធិការ ៧៣២២

០៦-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤០៧ ស្តីពីការតែងតាំងឯកឧត្តម **ខឡូ សាម៉ុន** ជាទីប្រឹក្សាអមក្រសួងផែនការ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៧៣២៣

០៦-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤០៨ ស្តីពីការតែងតាំងឯកឧត្តម **តើត រិទ្ធ** ជាអនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ជំនួសលោកជំទាវ **ចាន់ សុន្ធារី** ដែលត្រូវតែងតាំងជារដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ៧៣២៤

០៦-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤១០ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ លោកជំទាវ និងអស់លោក ចំនួន ០៣ រូប ៧៣២៥

II_រាជរដ្ឋាភិបាល

អនុក្រឹត្យ

០៦-៩-២០០៧ -អនុក្រឹត្យលេខ ១១៧ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៧៣២៦

០៧-៩-២០០៧ -អនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៧៣២៨

០៧-៩-២០០៧ -អនុក្រឹត្យលេខ ១១៩ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ៧៣៣០

១០-៩-២០០៧ -អនុក្រឹត្យលេខ ១២០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៧៣៣៨

១១-៩-២០០៧ -អនុក្រឹត្យលេខ ១២១ អនក្រ.បក ស្តីពីការលុបឈ្មោះ វិទ្យាស្ថានអន្តរជាតិ នៃកម្ពុជា ៧៣៤០
១១-៩-២០០៧ -អនុក្រឹត្យលេខ ១២២ អនក្រ.បក ស្តីពីការផ្ទេរគណនាធនថវិកា ៧៣៤២
១១-៩-២០០៧ -អនុក្រឹត្យលេខ ១២៣ អនក្រ.បក ស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈ ៧៣៤៤
១១-៩-២០០៧ -អនុក្រឹត្យលេខ ៧១៩ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៧៣៤៦
១១-៩-២០០៧ -អនុក្រឹត្យលេខ ៧២០ អនក្រ.តត ស្តីពីការតែងតាំងមុខងារនាយទាហាន ៧៣៤៨
១១-៩-២០០៧ -អនុក្រឹត្យលេខ ៧២១ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៧៣៥០
១១-៩-២០០៧ -អនុក្រឹត្យលេខ ៧២២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៣៦០
១២-៩-២០០៧ -អនុក្រឹត្យលេខ ៧២៣ អនក្រ.តតស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៧៣៦១
១២-៩-២០០៧ -អនុក្រឹត្យលេខ ៧២៤ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៧៣៦៣
១២-៩-២០០៧ -អនុក្រឹត្យលេខ ៧២៥ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៧៣៦៥
១២-៩-២០០៧ -អនុក្រឹត្យលេខ ៧២៦ អនក្រ.តត ស្តីពីការតែងតាំងមុខងារនាយទាហាន ៧៣៦៧

III.ការងារបណ្តាក្រសួង

១.ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

១២-៦-២០០៧ -ប្រកាសលេខ ៤៦៥ សហវ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជា ឆ្នាំ ២០០៧ (ត មកពីរាជកិច្ច លេខ ៤៩...ដល់...៦៧) ៧៣៦៩
០៣-៩-២០០៧ -ប្រកាសអន្តរក្រសួងលេខ ៨២៥ សហវ.ប្រក.ចមព ស្តីពីកម្រៃសេវាតម្កល់ និងស្រាវជ្រាវរកលិខិតជូនដំណឹង នៃប្រតិបត្តិការ ដែលមានកិច្ចធានា ៧៤១៤

២.ធនាគារជាតិ នៃ កម្ពុជា

ប្រកាស

២៧-៨-២០០៧ -ប្រកាសលេខ ធ៧-០៧-១៣២ ប្រក ស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៧៤១៨
២៧-៨-២០០៧ -ប្រកាសលេខ ធ៧-០៧-១៣៣ ប្រក ស្តីពីការអនុបាតសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៧៤២៥

២៧-៨-២០០៧ -ប្រកាសលេខ ធ៧-០៧-១៣៤ ប្រក ស្តីពីការត្រួតពិនិត្យស្ថានភាពចំហសុទ្ធ នៃរូបិយ
ប័ណ្ណចំពោះគ្រឹះស្ថាន ធនាគារ និង ហិរញ្ញវត្ថុ ៧៤៣១

២៧-៨-២០០៧ -ប្រកាសលេខ ធ៧-០៧-១៣៥ ប្រក ស្តីពីវិសោធនកម្មលើប្រកាស ស្តីពីអនុបាតសាធន
ភាពរបស់ធនាគារ ៧៤៣៨

៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

០៣-៩-២០០៧ -ប្រកាសលេខ ៩០៣ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន សាម អ៊ីល
អ៊ិនធើណេសិនណល បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះ
ថា " សាម អ៊ីល អ៊ិនធើណេសិនណល " ៧៤៤៤

០៤-៩-២០០៧ -ប្រកាសលេខ ៩០៤ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន លាន ម៉ី
(ខេមបូឌា) ហ្គាមេន បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះ
ថា " លាន ម៉ី (ខេមបូឌា) ហ្គាមេន " ៧៤៤៦

៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

០៧-៩-២០០៧ -ប្រកាសលេខ ២០៤ ប្រក ស្តីពីតួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ របស់នាយកដ្ឋាន
សំភារៈ និងបរិក្ខារ ៧៤៤៨

ព្រះរាជក្រឹត្យ

នស/រកត/០៨០៧/៣៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ដូរូស៊ីនគូ អូស្តាប់ (DOROSHENKO OSTAP) ជនជាតិរុស្ស៊ី សញ្ជាតិរុស្ស៊ី កើតនៅថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨២ នៅតំបន់អាល់ម៉ាលីក ក្រុងតាស្កែន ប្រទេសអ៊ូប៊ែកគីស្ថាន ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧០៨.៤២១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៧

លេខ: ៣៩៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនរតន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៧/៣៩៤

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសញ្ជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់ :

១- កុមារី **អេយី ញៀនចាន់អោងអែត សេរីន ស្វូង** (AYE NYEIN CHAN AUNG @ SERENE ZHUANG) ជនជាតិភូមា សញ្ជាតិភូមា កើតនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩២ នៅក្រុងយ៉ាងហ្គូន ប្រទេសភូមា ។

២- កុមារា **សេយ៉ា អោងអែត វីនសុន ស្វូង** (ZE YA AUNG @ VIN SON ZHUANG) ជនជាតិភូមា សញ្ជាតិភូមា កើតនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៨៨ នៅក្រុងយ៉ាងហ្គូន ប្រទេសភូមា ។

មាត្រា ២ : សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ

នរោត្ដម សីហមុនី

៣៩ល.០៧០៤.៤២២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៧

[illegible] លេខ ៤០០ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨០៧/៣៩៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ហូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់កញ្ញា **អេយី ធីតាអោងអែត វិចធ័រីយ៉ា ស្វង** (AYE THIDAR AUNG @ VICTORIA ZHAUNG) ជនជាតិភូមា សញ្ជាតិភូមា កើតនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ នៅក្រុងយ៉ាំងហ្គូន (YANGON) ប្រទេសភូមា ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៧០៨.៤២៣

លេខ: ៤០១ ច.ល
ថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ចិនកេង

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៧

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤០០

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកំរិតឧត្តម
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-

ត្រូវបានកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងធម្មការ និងសាសនា ដូចមានរាយនាមខាងក្រោម ÷

១	ញឹក តារាស្សី	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
២	ទ៉ា ស៊ីម៉េន	ស	អនុមន្ត្រី	ថ្នាក់លេខ ១៤
៣	សំ នា	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
៤	អន ស៊ីចន្ទ្រា	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
៥	សោម សុរាសី	ស	អនុមន្ត្រី	ថ្នាក់លេខ ១៤
៦	ហ៊ុន ច័ន្ទសុជាតា	ស	អនុមន្ត្រី	ថ្នាក់លេខ ១៤
៧	ឈុប អោម	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
៨	រុន សារី	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
៩	ពិ ប៊ុន្លីន	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
១០	ស សុខនី	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
១១	កែវ ណារុន	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
១២	ឃុន នីយ៉ារ៉ូ	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
១៣	ណៃ សីហា	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
១៤	អេង វិសាល	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
១៥	ផាត់ ច័ន្ទមុនីរដ្ឋា	ស	អនុមន្ត្រី	ថ្នាក់លេខ ១៤

មាត្រា ២.-

ត្រូវបានកំណត់ជាក្របខ័ណ្ឌគ្រូបង្រៀនកំរិតឧត្តម និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកំរិតឧត្តម តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងធម្មការ និងសាសនា ដូចមានរាយនាមខាង ក្រោម ÷

១	លី ទ៉ាន់នី	ប	គ្រូបង្រៀនកំរិតឧត្តម	ថ្នាក់លេខ ១៣
២	គង់ ផា	ប	គ្រូបង្រៀនកំរិតឧត្តម	ថ្នាក់លេខ ១៣
៣	ផាត រដ្ឋា	ប	គ្រូបង្រៀនកំរិតឧត្តម	ថ្នាក់លេខ ១៤
៤	ចែម វណ្ណី	ប	គ្រូបង្រៀនកំរិតឧត្តម	ថ្នាក់លេខ ១៤
៥	ស៊ុន ប៊ុនណាត	ប	គ្រូបង្រៀនកំរិតឧត្តម	ថ្នាក់លេខ ១៤

មាត្រា ៣.-

រាល់ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់មន្ត្រីរាជការស៊ីវិល នៅក្រោយពេលបញ្ចប់ការកំណត់ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌគ្រូបង្រៀនកំរិតឧត្តម ត្រូវអនុវត្តទាំងស្រុងតាមខ្លឹមសារដែលមានចែងក្នុងលក្ខន្តិកៈដោយឡែក ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ROYAUME du CAMBODGE
LE MINISTÈRE du PALAIS ROYAL

មាត្រា ៥.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៦.-

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខា តទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣/ល.០៧០៨.៤២៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៧

លេខៈ ៣៩៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ចិនកេន

KRET

NS / KRT / 0907/ 401

Nous

Preah Karuna Preah Bat Samdech
Preah Boromneath Norodom Sihamoni,
Roi du Cambodge

ÉLEVONS

Son Excellence Monsieur Sar Chanrithy
au rang de Directeur Général.

Norodom Sihamony

៣៧៧.០៧០៩.៤២៥

Fait au Palais Royal à Phnom Penh, le ៨ *Septembre 2007*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ [illegible] រ.ទម
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០៧
សម្ដេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧត្តម
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

MINISTÈRE DU PALAIS

កុង សំអុល

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤០២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

លោក គឹម ទួន

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បរ. ០៧០៩.៤២៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០០៧

លេខ: ៤០៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ចិនកេន

នស/រកត/០៩០៧/៤០៣

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **សាមួន ផន** ជាទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា នេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរល. ០៧០៩.៤២៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០០៧

លេខ ៤៧២ ច.ល
ដើម្បីចម្លងចែក
ភ្នំពេញ ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់ឯកឧត្តមប្រធានរដ្ឋសភាស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង ជាទីប្រឹក្សាឯកឧត្តម ង្វួន ញ៉ិល អនុប្រធានទី ១ នៃរដ្ឋសភា នីតិកាលទី៣ :

១- ឯកឧត្តម **នឹម សំអូល** ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

២- ឯកឧត្តម **នួយ ម៉ីន** ជាទីប្រឹក្សា មានឋានៈស្មើ **អគ្គនាយក** ។

មាត្រា ២ : ប្រធានរដ្ឋសភា និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា នេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧០៩.៤២៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០០៧

លេខ:៤១២៦ច.ល
...ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០៧
...រាជរដ្ឋាភិបាល
ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤០៥

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងថ្នាក់ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ជូនឯកឧត្ដម ម៉ៅ ភិរុណ ពីឧត្ដមមន្ត្រីថ្នាក់លេខ៣ ទៅឧត្ដមមន្ត្រីថ្នាក់លេខ ២ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខា នេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្ដម សីហមុនី

៣រល.០៧០៩.៤២៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០៧

លេខៈ ៤០៧ ច.ល

ចម្លងចែក

រាជធានីភ្នំពេញ ខែ កញ្ញា ឆ្នាំ២០០៧

រាជរដ្ឋាភិបាល

ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
-បានទ្រង់យល់សម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី៣ ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីលទ្ធផល នៃការបោះឆ្នោតទុកចិត្តលើការតែងតាំងសមាជិករាជរដ្ឋាភិបាលចំនួន ០៤ រូប
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង :

១-ឯកឧត្តម **ម៉ឹន ឈិន** ជាឧបនាយករដ្ឋមន្ត្រី
២-ឯកឧត្តម **ម៉េង សិរីវុឌ្ឍ** ជាទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
៣-លោកជំទាវ **ចាន់ សុផាវី** ជារដ្ឋលេខាធិការក្រសួងយុត្តិធម៌
៤-ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ គេសរ្វ** ជារដ្ឋលេខាធិការក្រសួងទេសចរណ៍

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៧០៩.៤៣០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០៧

[illegible]០៥ច.ល
[illegible]ចម្លងចែក
[illegible] ខែ កញ្ញា ឆ្នាំ២០០៧
[illegible]រាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងឯកឧត្តម ខង សាម៉ុន ជាទីប្រឹក្សាអមក្រសួងផែនការ មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧០៩.៤៣១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ , ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០៧

លេខ: ៤០៧ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤០៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានតែងតាំងឯកឧត្តម កើត រិទ្ធ ជាអនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ជំនួសលោកជំទាវ ចាន់ សុខ្លាទី ដែលត្រូវតែងតាំងជារដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ។

មាត្រា ២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខ: ៤០៤ច.ល
ថតចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ីន កេន

ពរល.០៧០៩.៤៣២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ , ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០៧

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

- លោកជំទាវ ជា ស្វផាម៉ាំដែន

-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :

១- លោក ជួត ឃួត

២- លោក ឃួន សេង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៧.០៧០៩.៤៣៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០៧

លេខៈ ៤១៣ ច.ល
ដើម្បីចម្លងចែក
ភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០៧
...រាជរដ្ឋាភិបាល
... ចិនកេន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០១៣៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ .ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៥៣៨.៨៦១.៦០០ រៀល (ប្រាំរយសាមសិបប្រាំបីលានប្រាំបីរយហុកសិបមួយពាន់ប្រាំមួយរយរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៥ (ឧបត្ថម្ភធន និង ជំនួយសង្គម) ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីទូទាត់សងផ្តាច់បុរេប្រទាន សំរាប់បើកប្រាក់បៀវត្សប្រចាំខែ មករា-កុម្ភៈឆ្នាំ ២០០៥ ជូនកម្មកររោងចក្រសាំហាន់ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១៧...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ២៤៥.០០០.០០០រៀល (ពីររយសែសិបប្រាំលានរៀលគត់) ពីជំពូក ៦២ (សេវាខាងក្រៅផ្សេងៗ) មកជំពូក ៦១ (សេវាខាងក្រៅ) ជូនក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បំពេញបន្ថែមសោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ឆ្នាំ ២០០៧ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទទួលយល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- យោងតាមសំណើរបស់ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ កំណត់រចនាសម្ព័ន្ធ មុខងារ និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ហៅកាត់ថា អគ្គលេខាធិការដ្ឋាន "**គបស**" ដែលជាសេនាធិការបច្ចេកទេសសម្រាប់គាំទ្រដំណើរការរបស់ **គបស** ។

ជំពូកទី ២

មុខងារ និង ភារកិច្ច

មាត្រា ២.-

អគ្គលេខាធិការដ្ឋាន **គបស** គឺជាស្ថាប័នប្រតិបត្តិ ក្នុងការបំពេញមុខងារ និង ភារកិច្ចដូចតទៅ :

- ពិនិត្យ និងរៀបចំសេចក្តីព្រាងឯកសារ និងសុន្ទរកថាសំខាន់ៗ ព្រមទាំងគម្រោងសិក្សា ស្រាវជ្រាវ និងរបាយការណ៍សង្គម-សេដ្ឋកិច្ចទាំងឡាយ តាមការសម្រេចរបស់ **គបស** ស្របតាមការចង្អុលទិសរបស់ប្រមុខរាជរដ្ឋាភិបាល
- រៀបចំយុទ្ធសាស្ត្រតាមការណែនាំរបស់ **គបស** ក្នុងទិសដៅកែលំអការគ្រប់គ្រងសង្គម-សេដ្ឋកិច្ច និងពង្រឹងអភិបាលកិច្ច
- ពិនិត្យ តាមដាន និងបូកសរុបការអនុវត្តការងារកែទម្រង់ និងគំនិតផ្តួចផ្តើមនានា ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដែលប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញដោយផ្ទាល់ និងរាយការណ៍ជូន **គបស** ពិនិត្យ និងលើកជាអនុសាសន៍ ជូនប្រមុខរាជរដ្ឋាភិបាល
- ពិនិត្យ តាមដាន និងបូកសរុបរបាយការណ៍នានា ដែលពាក់ព័ន្ធនឹងការអនុវត្តផែនការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច និងកម្មវិធីអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាល និងរាយការណ៍ជូន **គបស** ដើម្បីពិនិត្យ និងលើកជាអនុសាសន៍ ជូនប្រមុខរាជរដ្ឋាភិបាល សំដៅតម្រង់ទិស និងបង្កើនល្បឿនអនុវត្តផែនការ និងកម្មវិធីទាំងនោះ
- សិក្សា ស្រាវជ្រាវ អំពីស្ថានការណ៍សេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចអន្តរជាតិ និងធ្វើរបាយការណ៍សង្ខេបជូន **គបស** ដើម្បីពិនិត្យ និងផ្តល់ជាអនុសាសន៍ ជូនប្រមុខរាជរដ្ឋាភិបាលសំដៅសម្របសម្រួលដំណើរការនយោបាយសេដ្ឋកិច្ចជាតិ ឱ្យស្របទៅតាមនិន្នាការវិវត្តន៍ នៃសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចអន្តរជាតិ
- វិភាគ លើកគម្រោង និងអនុវត្តការងារសិក្សាស្រាវជ្រាវគោលនយោបាយអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៅក្នុង និងរវាងវិស័យនានា តាមការសម្រេចរបស់ **គបស** និងក្រោមការចង្អុលទិសរបស់ប្រមុខ

រាជរដ្ឋាភិបាល សំដៅធានាឱ្យបាននូវគុណភាព សង្គតិភាព និងភាពរលូននៃគោលនយោបាយអភិវឌ្ឍន៍ជារួមរបស់រាជរដ្ឋាភិបាល និងរាយការណ៍ជូន **កបស** ដើម្បីពិនិត្យ និងផ្តល់យោបល់ជូនប្រមុខរាជរដ្ឋាភិបាល

- គ្រប់គ្រងមជ្ឈមណ្ឌលធនធាន និងឯកសារ ដែលពាក់ព័ន្ធទៅនឹងការងាររបស់ **កបស** រួមមានឯកសារផ្លូវការ ឯកសារសម្រាប់ការស្រាវជ្រាវ របាយការណ៍ និងផែនការសកម្មភាពនានា
- គ្រប់គ្រងការងាររដ្ឋបាល មន្ត្រីបុគ្គលិកនៃអគ្គលេខាធិការដ្ឋាន ថវិកា ព្រមទាំងទ្រព្យសម្បត្តិ និងធនធាននានា ដែលផ្គត់ផ្គង់ដោយថវិកាជាតិ និងមូលនិធិ ដែលបានមកពីប្រភពក្នុង និងក្រៅប្រទេស
- រៀបចំកិច្ចប្រជុំវគ្គសិក្សាបណ្តុះបណ្តាល សិក្ខាសាលា និងសន្និសីទនានារបស់ **កបស**
- បំពេញការងារផ្សេងទៀត តាមការណែនាំរបស់ប្រធាន **កបស** ។

ជំពូកទី ៣

រចនាសម្ព័ន្ធ និង ការគ្រប់គ្រង

មាត្រា ៣.-

អគ្គលេខាធិការដ្ឋាន **កបស** ស្ថិតនៅក្រោមការដឹកនាំរបស់អគ្គលេខាធិការមួយរូប មានឋានៈស្មើរដ្ឋលេខាធិការ និងអគ្គលេខាធិការរងមួយចំនួន ជាជំនួយការ តាមសេចក្តីត្រូវការចាំបាច់ ដែលអាចមានឋានៈស្មើអនុរដ្ឋលេខាធិការ ឬ អគ្គនាយក ។

មាត្រា ៤.-

សមាជិកអគ្គលេខាធិការដ្ឋាន **កបស** គឺជាមន្ត្រីរាជការ ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដែលមានលក្ខណៈវិនិច្ឆ័យ ដូចតទៅ :

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ
- មានសមត្ថភាពជំនាញខ្ពស់
- មានចំណេះដឹងផ្នែកភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន ។

សមាជិកអគ្គលេខាធិការដ្ឋាន **កបស** មានឋានៈ និងបុព្វសិទ្ធិស្មើ អគ្គនាយករង ឬ ប្រធាននាយកដ្ឋាន ។ ដោយឡែកប្រធានផ្នែកនីមួយៗ នៃអគ្គលេខាធិការដ្ឋាន **កបស** មានឋានៈ និងបុព្វសិទ្ធិស្មើ អគ្គនាយក និងអនុប្រធានផ្នែក មានឋានៈ និង បុព្វសិទ្ធិស្មើ អគ្គនាយករង ។

ក្នុងករណីចាំបាច់ **កបស** អាចមានអ្នកជំនាញ ឬ បុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងារក្នុងអគ្គលេខាធិការដ្ឋានរបស់ខ្លួន ។

មាត្រា ៥.-

អគ្គលេខាធិការដ្ឋាន **កបស** មានរចនាសម្ព័ន្ធ ដូចតទៅ:

១-ផ្នែកសិក្សា និង វិភាគគោលនយោបាយសេដ្ឋកិច្ច :

ផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច មានតួនាទី និងភារកិច្ច ដូចតទៅ:

- លើកឡើងនូវគំនិតផ្តួចផ្តើមទាំងឡាយ ដែលមានចរិតជាចក្ខុវិស័យ និងគោលនយោបាយអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សិក្សា និងវិភាគអំពីគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល សំដៅធានាឱ្យបាននូវគុណភាព សង្គតិភាព និងភាពរលូន នៅក្នុងគោលនយោបាយវិស័យនេះ និងរវាងវិស័យនេះ ជាមួយវិស័យផ្សេងទៀត
- សិក្សា និងវិភាគអំពីស្ថានការណ៍សេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចអន្តរជាតិ សំដៅសម្របសម្រួលដំណើរការនយោបាយសេដ្ឋកិច្ចជាតិឱ្យស្របទៅតាមនិន្នាការវិវត្តន៍ នៃសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចអន្តរជាតិ
- ពិនិត្យ និងតាមដានការងារកែទម្រង់ និងគំនិតផ្តួចផ្តើមនានា ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញដោយផ្ទាល់
- ចូលរួមពិនិត្យ តាមដាន និងផ្តល់យោបល់នៅក្នុងអង្គប្រជុំអន្តរក្រសួង និងអង្គប្រជុំផ្សេងៗ ដែលរៀបចំឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រី និងដោយក្រសួងស្ថាប័ននានា ទាក់ទងនឹងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំគំរូសេដ្ឋកិច្ច រួមទាំងការវិភាគ និងព្យាករណ៍សេដ្ឋកិច្ច
- បូកសរុប និងធ្វើរបាយការណ៍ប្រចាំឆ្នាំ អំពីស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងផ្តល់ជាអនុសាសន៍ដើម្បីពង្រឹងវិស័យនេះ
- ពិនិត្យ និងរៀបចំសេចក្តីព្រាងសុន្ទរកថា និងរបាយការណ៍ផ្សេងៗ ពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការណែនាំរបស់អគ្គលេខាធិការ **គបស** ឬ តាមការណែនាំរបស់ប្រធាន **គបស**
- ទទួលខុសត្រូវក្នុងការរៀបចំ និង អនុវត្តការងារសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រៀបចំ និង ចងក្រងទិន្នន័យ ឯកសារផ្សេងៗ សម្រាប់ការសិក្សា និង ស្រាវជ្រាវ ក្នុងវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច ដឹកនាំដោយប្រធានមួយរូប ដែលមានឋានៈស្មើ អគ្គនាយក អមដោយអនុប្រធានមួយចំនួន ជាជំនួយការ តាមសេចក្តីត្រូវការចាំបាច់ ដែលមានឋានៈស្មើ អគ្គនាយករង ។

២-ផ្នែកសិក្សា និង វិភាគគោលនយោបាយសង្គមកិច្ច :

ផ្នែកសិក្សា និង វិភាគគោលនយោបាយសង្គមកិច្ច មានតួនាទី និង ភារកិច្ច ដូចតទៅ:

- លើកឡើងនូវគំនិតផ្តួចផ្តើមទាំងឡាយ ដែលមានចរិតជាចក្ខុវិស័យ និងគោលនយោបាយអភិវឌ្ឍន៍វិស័យសង្គមកិច្ច

- សិក្សា និងវិភាគអំពីគោលនយោបាយសង្គមកិច្ចរបស់រាជរដ្ឋាភិបាល សំដៅធានាឱ្យបាននូវគុណភាព សង្គតិភាព និងភាពរលូន នៅក្នុងគោលនយោបាយវិស័យនេះ និងរវាងវិស័យនេះ ជាមួយវិស័យផ្សេងទៀត
- ពិនិត្យ និងតាមដានការងារកែទម្រង់ និងគំនិតផ្តួចផ្តើមនានា ក្នុងការអភិវឌ្ឍវិស័យសង្គមកិច្ច ដែលប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញដោយផ្ទាល់
- ចូលរួមពិនិត្យ តាមដាន និងផ្តល់យោបល់នៅក្នុងអង្គប្រជុំអន្តរក្រសួង និងអង្គប្រជុំផ្សេងៗ ដែលរៀបចំឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រី និងដោយក្រសួងស្ថាប័ននានា ទាក់ទងនឹងវិស័យសង្គមកិច្ច
- ប្រមូលសរុប និងធ្វើរបាយការណ៍ប្រចាំឆ្នាំ អំពីស្ថានភាពសង្គមកិច្ច និងផ្តល់ជាអនុសាសន៍ ដើម្បីពង្រឹងវិស័យនេះ
- ពិនិត្យ និងរៀបចំសេចក្តីព្រាងសុន្ទរកថា និងរបាយការណ៍ផ្សេងៗពាក់ព័ន្ធនឹងវិស័យសង្គមកិច្ច ជូនប្រមុខរាជរដ្ឋាភិបាល តាមការណែនាំរបស់អគ្គលេខាធិការ **គបស** ឬ តាមការណែនាំរបស់ប្រធាន **គបស**
- ទទួលខុសត្រូវក្នុងការរៀបចំ និងអនុវត្តការងារសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងវិស័យសង្គមកិច្ច
- រៀបចំ និងចងក្រងទិន្នន័យ ឯកសារផ្សេងៗ សម្រាប់ការសិក្សា និងស្រាវជ្រាវ ក្នុងវិស័យសង្គមកិច្ច ។

ផ្នែកសិក្សា និងវិភាគគោលនយោបាយសង្គមកិច្ច ដឹកនាំដោយប្រធានមួយរូប ដែលមានឋានៈស្មើអគ្គនាយក អមដោយអនុប្រធានមួយចំនួន ជាជំនួយការ តាមសេចក្តីត្រូវការចាំបាច់ ដែលមានឋានៈស្មើអគ្គនាយករង ។

៣-ផ្នែកសិក្សា និង វិភាគគោលនយោបាយអភិបាលកិច្ច :

ផ្នែកសិក្សា និង វិភាគគោលនយោបាយអភិបាលកិច្ច មានតួនាទី និង ភារកិច្ច ដូចតទៅ :

- លើកឡើងនូវគំនិតផ្តួចផ្តើមទាំងឡាយ ដែលមានចរិតជាចក្ខុវិស័យ និងគោលនយោបាយអភិវឌ្ឍន៍វិស័យអភិបាលកិច្ច
- វិភាគ សិក្សា ស្រាវជ្រាវ រកយន្តការនានា សំដៅជំរុញកែលំអការគ្រប់គ្រង និងពង្រឹងអភិបាលកិច្ច ជាពិសេស ក្នុងវិស័យការងារកែទម្រង់ច្បាប់ ប្រព័ន្ធតុលាការ និងរដ្ឋបាលសាធារណៈ
- ពិនិត្យ តាមដានលទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់វិស័យអភិបាលកិច្ច ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលផ្ទាល់
- ចូលរួមពិនិត្យ តាមដាន និងផ្តល់យោបល់នៅក្នុងអង្គប្រជុំអន្តរក្រសួង និងអង្គប្រជុំផ្សេងៗ ដែលរៀបចំឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រី និងដោយក្រសួងស្ថាប័ននានា ទាក់ទងនឹងវិស័យអភិបាលកិច្ច ជាអាទិ៍លើវិស័យច្បាប់ ប្រព័ន្ធតុលាការ និងរដ្ឋបាលសាធារណៈ
- ទទួលខុសត្រូវក្នុងការរៀបចំ និងអនុវត្តការងារសិក្សាស្រាវជ្រាវ ពាក់ព័ន្ធនឹងវិស័យអភិបាលកិច្ច

- បូកសរុប និងធ្វើរបាយការណ៍ប្រចាំឆ្នាំអំពីស្ថានភាពវិវត្តន៍នៃវិស័យអភិបាលកិច្ច និងផ្តល់ជាអនុសាសន៍ដើម្បីពង្រឹងវិស័យនេះ
- ពិនិត្យ សិក្សា វិភាគ និងផ្តល់យោបល់លើសំណុំរឿងផ្សេងៗ ព្រមទាំងបំពេញការងារដទៃទៀតតាមការណែនាំរបស់ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ពិនិត្យ និងរៀបចំសេចក្តីព្រាងសុន្ទរកថា និងរបាយការណ៍ផ្សេងៗ ពាក់ព័ន្ធនឹងវិស័យអភិបាលកិច្ចតាមការណែនាំរបស់អគ្គលេខាធិការ **កបស** ឬ តាមការណែនាំរបស់ប្រធាន **កបស**
- រៀបចំ និងចងក្រងទិន្នន័យ ឯកសារផ្សេងៗ សម្រាប់ការសិក្សា និងស្រាវជ្រាវទាក់ទងនឹងវិស័យអភិបាលកិច្ច ។

ផ្នែកសិក្សា និងវិភាគគោលនយោបាយអភិបាលកិច្ច ដឹកនាំដោយប្រធានមួយរូប ដែលមានឋានៈស្មើអគ្គនាយក អមដោយអនុប្រធានមួយចំនួន ជាជំនួយការ តាមសេចក្តីត្រូវការចាំបាច់ ដែលមានឋានៈស្មើអគ្គនាយករង ។

៤-ផ្នែកបុគ្គលិករដ្ឋបាល និង ហិរញ្ញវត្ថុ :

ផ្នែកបុគ្គលិករដ្ឋបាល និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ច ដូចតទៅ :

- រៀបចំផែនការគ្រប់គ្រងបុគ្គលិក មន្ត្រីរាជការ និងធនធានមនុស្ស ជាពិសេសរៀបចំផែនការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពការងារ និងជំនាញឱ្យបានស៊ីជម្រៅ ក្នុងគោលដៅអនុវត្តការងារឱ្យមានប្រសិទ្ធភាព
- ពិនិត្យរៀបចំសំណើលើកទឹកចិត្ត ដល់បុគ្គលិកមន្ត្រីរាជការ ដែលមានស្នាដៃល្អ ក្នុងការបំពេញការងារ
- គ្រប់គ្រងការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន **កបស**
- គ្រប់គ្រង និងរៀបចំវគ្គសិក្សា ឬ សិក្ខាសាលាតាមការណែនាំរបស់អគ្គលេខាធិការ **កបស** ឬ តាមការណែនាំរបស់ប្រធាន **កបស**
- រៀបចំការប្រជុំ និងធ្វើកំណត់ហេតុអង្គប្រជុំរបស់ **កបស** និងរាយការណ៍ អំពីលទ្ធផលនៃការប្រជុំជូនមន្ត្រីពាក់ព័ន្ធរបស់ **កបស** ដើម្បីជ្រាបជាព័ត៌មាន និងអនុវត្តឱ្យមានប្រសិទ្ធភាពតាមស្មារតី និងការសម្រេចរបស់អង្គប្រជុំ **កបស**
- ផ្គត់ផ្គង់នូវតម្រូវការផ្សេងៗ សម្រាប់ការប្រជុំសាមញ្ញ វិសាមញ្ញ ព្រមទាំងវគ្គសិក្សា សិក្ខាសាលាសន្និសីទនានាតាមការចាំបាច់
- រៀបចំរបាយការណ៍បូកសរុបការងារប្រចាំឆមាស របស់អគ្គលេខាធិការដ្ឋាន **កបស** ជូនឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីពិនិត្យ វាយតម្លៃ និងផ្តល់ការណែនាំ
- រៀបចំអភិវឌ្ឍន៍យុទ្ធសាស្ត្រ និងគ្រប់គ្រងព័ត៌មានវិទ្យារបស់ **កបស**
- ពិនិត្យ តាមដាន ថែរក្សាប្រព័ន្ធព័ត៌មានវិទ្យារបស់ **កបស**

- ធានាប្រសិទ្ធភាពការងាររដ្ឋបាល សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់របស់ **គបស**
- រៀបចំលិខិតរដ្ឋបាល រក្សាទុកសំណុំឯកសាររបស់មន្ត្រី បុគ្គលិក និងទទួលខុសត្រូវលើលិខិតចេញចូលរបស់ **គបស**
- គ្រប់គ្រងសៀវភៅ ឯកសារសិក្សាស្រាវជ្រាវ ច្បាប់ លិខិតបទដ្ឋាននានា និងសម្ភារៈបរិក្ខារនៃមជ្ឈមណ្ឌលធនធាន និងឯកសារ **គបស**
- ទំនាក់ទំនងជាមួយផ្នែកពាក់ព័ន្ធនៃក្រសួង-ស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីអភិវឌ្ឍការងាររបស់ **គបស**
- ទទួលខុសត្រូវក្នុងការបោះពុម្ព និងផ្សព្វផ្សាយនូវឯកសារសិក្សាស្រាវជ្រាវរបស់ **គបស**
- លើកគម្រោងថវិកា និងគ្រប់គ្រងរាល់ចំណូល ចំណាយ ដើម្បីធានាការប្រព្រឹត្តទៅរបស់ **គបស**
- គ្រប់គ្រងថវិកា ទ្រព្យសម្បត្តិ និងធនធាននានា ដែលផ្គត់ផ្គង់ដោយថវិកាជាតិ ព្រមទាំងមូលនិធិដែលបានមកពីប្រភពក្នុង និងក្រៅប្រទេស ។

ផ្នែកបុគ្គលិករដ្ឋបាល និងហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប ដែលមានឋានៈស្មើ អគ្គនាយក អមដោយអនុប្រធានមួយចំនួន ជាជំនួយការ តាមសេចក្តីត្រូវការចាំបាច់ ដែលមានឋានៈស្មើ អគ្គនាយករង ។

ជំពូកទី ៤

អវសានប្បញ្ញត្តិ

មាត្រា ៦.-

អនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកញ្ញា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៧

អង្គការលេខរបស់អគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៧០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤, ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣, ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស /៩៤, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥, ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាស ឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម /១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយ ច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦ /០៣៥, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក. ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយ ចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១ : ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៨០.០០០.០០០ រៀល (ប៉ែតសិបលានរៀលគត់)ពីជំពូក៦១ (សេវាខាងក្រៅ) មកជំពូក ៦០ (ការទិញ) ជូនតុលាការកំពូល សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២ : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបំពេញតំរូវការចំណាយជាក់ស្តែង របស់តុលាការកំពូល សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លោកប្រធានតុលាការកំពូល ជាអ្នកទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីគោរពជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧១ .អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការលុបឈ្មោះវិទ្យាស្ថានអន្តរជាតិនៃកម្ពុជា

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៧/១២៩ ចុះថ្ងៃទី៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់ គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រង គ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
